# ឧ ត្ត ម ភ រិ យា

ឯប្រពន្ធជា ឯកឈ្មោះមាតា ភរិយាដូចម្ដាយ ឈឺឆ្អាលកូនខ្លួន វែងស្ងួនមិនណាយ មិននឹករសាយ ចិត្តចាំអាណិត។

កូនទុក្ខទោសម្ដេច ខ្សត់ក្រច្រើនតិច ខឹងខុសខូចចិត្ត ព្រាត់ប្រាសយូរលង់ ពុំបង់បែកចិត្ត គង់ចាំចិត្តគិត ឈឺឆ្អាលកូនស្មោះ។

ប្រពន្ធណាគាប់ ឈឺឆ្អាលប្ដីខ្ជាប់ ចិត្តចាំកាន់កោះ ដូចម្ដាយស្រឡាញ់ កូនពេញពីពោះ ហៅប្រពន្ធនោះ ថ្លៃឥតផ្ទឹមដល់។

ប្រពន្ធជាទ្វិ ឈ្មោះហៅវាសី ភរិយាដូចកល់ ខ្ញុំនឹងអម្ចាស់ ប្រើណាស់ខ្វាយខ្វល់ អាចអត់ទប់ទល់ ទម្ងន់បម្រើ។

មិនមានទំនេរ ហត់នឿយកាយេ អត់ឱនសារពើ តាមតែបង្គាប់ ប្រញាប់ចង់ធ្វើ ចិត្តពុំសើរើ ចៀសវាងក្រោធា។

ប្រពន្ធណាអត់ ឱនអង្គអំណត់ ខ្លាចប្ដីអាត្មា ដូចខ្ញុំនឹងម្ចាស់ ខ្លាចណាស់ធានា ប្រពន្ធនោះជា ប្រសើរសុខសួន។

ប្រពន្ធជាត្រី ឈ្មោះភគិនី ភរិយាដូចប្អូន ស្រឡាញ់បងពិត លំអិតលំអួន ទទួលដំបូន មានមាត់ពាក្យបង។

ផ្ដាច់ផ្ដួលតែមួយ នឹងចងជាត្រួយ ចិត្តចាំបំណង ពំនាក់ពំនឹង ពាក់ពឹងប៉ុនប៉ង តែនឹងអង្គបង ឥតម៉ែទីទៃ។

ប្រពន្ធណាចូល នឹងប្ដីមួយមូល ចិត្តជាប់អាល័យ ដូចប្អូននឹងបង ចាំចងអាស្រ័យ ប្រពន្ធនោះថ្លៃ មធ្យមពេកពិត។

ប្រពន្ធចត្វា ឈ្មោះហៅសាខា ភរិយាដូចមិត្ត សំឡាញ់ស្រឡាញ់ អស់អញពេកពិត ស្មើខ្លួនស្មើចិត្ត ស្ម័គ្រស្មោះចិន្ដា។

បើមិត្រទៅបាត់ ស្ងប់ស្ងួតមុខមាត់ ទុក្ខទន់ទយា ឃើញមុខមកបាន ចិត្តក្សាន្តសោះសា ស្រស់ស្រួលភត្ត្រា និរទុក្ខសោកសៅ។

ប្រពន្ធណាចិត្ត ស្រឡាញ់ប្ដីពិត គ្មានក្នុងគ្មានក្រៅ ដូចមិត្តនឹងមិត្រ ចងចិត្តជាប់នៅ ប្រពន្ធនោះហៅ ឧត្តមក្រមាន។

សម្ដែងភរិយា ទាំងបួនសឹងជា ក្រស្រីធ្វើបាន បើស្រីណាគិត ផ្ចង់ចិត្តសន្តាន ធ្វើទាំងបួនបាន ឧត្តមកន្លង។៕

នេះជាច្បាប់ប្រដៅ មនុស្សស្រី ឬកូនស្រី ដែលខ្ញុំបាទ អាចារ្យ សុខ ផុន បានសិក្សាតាំងពីខ្ញុំបាទនៅវ័យជាកុមារភាប មិនមានចម្លងតាមសៀវភៅណាឡើយ ក្នុងបច្ចុប្បន្ននេះ។ បើបងប្អូនញាតិមិត្រណាបានឃើញត្រង់កន្លែងនាដែលខុស សូមលោកជួយកែសម្រួលផង.

ខ្ញុំសូមអរគុណទុកជាមុន សរសេរនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១២ អាចារ្យ សុខ ផុន

វាយចម្លងដាក់គេហទំព័រវត្ត ឧត្តមភរិយា ដោយខ្ញុំបាទ អ៊ិន លី ថ្ងៃទី៨ ខែមីនា ឆ្នាំ២០១២